**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២៥៧/អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីសរុបទំហំ ៨ ៩០៤ ហិកតា នៅក្នុងស្រុកទឹកផុស ស្រុកបរិបូណ៌ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងរក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០៧២ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៩០៧ ខ.ពស ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៨.៩០៤ ហិកតា ក្នុងនោះ (១) ទំហំ ១.៨២០ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ (២) ទំហំ ៦ ១៨៨ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច (៣)ទំហំ ៦៦៦ ហិកតា ពីស្ថានីយ៍កូនឈើម្សៅក្រដាស ហ៊ុន សែន មានក និង(៤) ទំហំ ២៣០ ហិកតា ពីដីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៧.៨៧៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.០២៦ ហិកតារក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ ស្ថិតនៅក្នុងភូមិឃុំស្រុកដូចខាងក្រោម៖

- ផ្ទៃដីសរុបទំហំ ១ ១៦១ ហិកតា កាត់ចេញដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៩៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២០៧ ហិកតារក្សាទុកជាដីព្រៃបំរុងសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងភូមិ ក្រាំងទងឃុំទួលខ្ពស់ ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៨៨៨ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៨៨៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងពុំមានរក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើនៅភូមិជីពួក ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៤៧៦ ហិកតា ក្នុងនោះ ទំហំ ២១៦ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងទំហំ ២៦០ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៤២៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៨ ហិកតា



p

រក្សាទុកជាដីបម្រុង សម្រាប់សហគមន៍ព្រៃឈើ នៅភូមិតាំងខ្យា ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ

- ផ្ទៃដីសរុបទំហំ ២៦៣៧ ហិកតា ក្នុងនោះ: (១) ទំហំ ១.០០២ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ទំហំ ១.៤០៥ ហិកតា កាត់ចេញពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និង(៣) ទំហំ ២៣០ ហិកតា ពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៤៦៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៧០ ហិកតា រក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ នៅភូមិក្រសាំងដុះឡើង ឃុំក្បាលទឹក ស្រុកទឹកផុស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៤) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ១៧៨៧ ហិកតា ក្នុងនោះ: ទំហំ ១១៤ ហិកតា កាត់ចេញដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងទំហំ ១.៦៧៣ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ១.៤៣៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៤៨ ហិកតា រក្សាទុកជាដីបម្រុងសម្រាប់សហគមន៍ព្រៃឈើ នៅក្នុងភូមិក្តុល ឃុំក្រាំងស្គារ ស្រុកទឹកផុសតាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៥) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ១៦៨៩ ហិកតា កាត់ចេញដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១.៤៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩៤ ហិកតា រក្សាទុកជាដីព្រៃបំរុងសម្រាប់ សហគមន៍ព្រៃឈើ នៅក្នុងភូមិ អញ្ចាញរូង ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៦) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៦៦៦ ហិកតា កាត់ចេញដីស្ថានីយកូនឈើម្សៅក្រជាស ហ៊ុន សែន មានកនិងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៦០៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥៩ ហិកតា រក្សាទុកជាដីព្រៃបំរុង សម្រាប់សហគមន៍ព្រៃឈើ ស្ថិតនៅក្នុងភូមិ មានកលិច ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៧) នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣.០៧៨ គ្រួសារ នៅក្នុងស្រុកទឹកផុស ស្រុកបរិបូណ៌ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥០៣ គ្រួសារ នៅភូមិរកាទង ឃុំ ទូលខ្ពស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៤ គ្រួសារ នៅភូមិជីពូក ឃុំក្បាលទឹក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៨ គ្រួសារ នៅភូមិតាំងខ្យា ឃុំក្បាលទឹក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៨៩ គ្រួសារ នៅភូមិក្រសាំងដុះឡើង ឃុំក្បាលទឹក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦២ គ្រួសារ នៅភូមិក្តុល ឃុំក្រាំងស្គារ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៣៥ គ្រួសារ នៅភូមិអញ្ចាញរូង ឃុំអញ្ចាញរូង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦២ គ្រួសារ នៅភូមិមានកលិច ឃុំត្បែងខ្ពស់ ។



p

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ៥ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ



p